ការបំពេញការងារក្នុងអាណត្តិទី៧នេះ គឺជាការបន្តមរតកសមិទ្ធផល នៃរដ្ឋបុរសរបស់កម្ពុជា ពិសេស **ព្រះករុណាព្រះបាទសម្តេចព្រះបរមរតនកោដ្ឋ** ដែលបានទាមទារឯករាជ្យជាតិ បន្តមកដំណាក់កាលដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានតស៊ូលះបង់គ្រប់បែបយ៉ាងដើម្បីរំដោះជាតិ និងអភិវឌ្ឍប្រទេសរហូតដល់ទទួលបាន **ឯកភាពជាតិ និងសុខសន្តិភាពពេញលេញ** ហើយបានបន្តដំណើរមកដល់**សហសម័យកម្ពុជា** ដែលជាយុគសម័យទំនើប នៃការបន្តដំណើររីកចម្រើនទៅមុខ ក្រោមការដឹកនាំរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។

**ផ្អែកលើអាទិភាព នៃយុទ្ធសាស្ត្របញ្ចកោណ ក្នុងបញ្ចកោណទី៤ មុំទី៤ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្តោតលើទិសដៅអាទិភាពគោលនយោបាយ ១៥ចំណុច សម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៧**

**អទិភាពទី១ ÷ ការងាររៀបចំគោលនយោបាយ** ឱ្យកាន់តែមានភាពជាក់ស្តែង និងអនុវត្តឆ្ពោះទៅរកលទ្ធផល។

**អទិភាពទី២ ÷ ការងាររៀបចំក្របខ័ណ្ឌគតិយុត្ត** ដោយពិនិត្យកែលម្អ បំពេញបន្ថែម និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋាន គតិយុត្តឱ្យបានកាន់តែពេញលេញស្របតាមបរិបទថ្មី និងមានភាពជាក់ស្តែងនិយមមានសង្គតិភាព ពិសេសការរៀបចំសេចក្តីព្រាងច្បាប់សំខាន់ៗមួយចំនួន រួមមាន÷ (១). ច្បាប់ភូមិបាល ដោយត្រូវរៀបចំឡើងវិញទាំងស្រុង (២). ច្បាប់ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម ជាច្បាប់ថ្មីមិនធ្លាប់មាន (៣). ច្បាប់ស្តីពីលំនៅឋានជាច្បាប់ថ្មីមិនធ្លាប់មាន។

**អទិភាពទី៣ ÷ ការកសាងស្ថាប័ន និងរដ្ឋបាលសាធារណៈទំនើប** ដែលអនុញ្ញាតឱ្យប្រព័ន្ធការងារប្រចាំថ្ងៃមានដំណើរ ការដោយយប្រវត្តិប្រសិទ្ធភាព ។

**អទិភាពទី៤ ÷ ការលើកកម្ពស់សេវាសាធារណៈទំនើប និងការគ្រប់គ្រងទិន្នន័យ** ដើម្បីផ្តល់សេវាលឿនរហ័ស តម្លាភាព ប្រសិទ្ធភាព ងាយស្រួល និងជឿទុកចិត្ត។

**អទិភាពទី៥ ÷ ការងារចុះបញ្ជីដីធ្លី ដើម្បី**បន្តផ្តល់ប័ណ្ណកម្មសិទ្ធិដល់ប្រជាជនឱ្យបានលឿន ដើម្បីជាមូលដ្ឋានប្រភពសេដ្ឋកិច្ច និងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី។

**អទិភាពទី៦ ÷ ការរៀបចំដែនដី** ស្របតាមទិសការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមឱ្យមានប្រសិទ្ធភាពនិងចីរភាព ពិសេសស្របតាមរបៀងសេដ្ឋកិច្ចដោយផ្អែកលើតំបន់អភិរក្ស តំបន់បេតិកភណ្ឌ តំបន់កសិកម្ម តំបន់ឧស្សាហកម្ម លំនៅឋាន តំបន់ដីសាធារណៈសម្រាប់ចម្រុងទុក ដីសម្រាប់សួន សាធារណៈ តំបន់បៃតង។ល។

**អទិភាពទី៧ ÷ ការអភិវឌ្ឍនគរូបនីយកម្ម** តាមរយៈការរៀបចំផែនការអភិវឌ្ឍទីក្រុង ទីប្រជុំជន នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅទូទាំងរាជធានី-ខេត្ត ឱ្យបានចប់សព្វគ្រប់ស្របទៅតាមទស្សនាទានទីក្រុងស្អាត ទីក្រុងឆ្លាត និងទីក្រុងគួរឱ្យចង់រស់នៅ។

**អទិភាពទី៨ ÷ ស្ថាបត្យកម្មខ្មែរសហសម័យ** ដោយជំរុញការសាងសង់ដោយយករចនាបថខ្មែរមកប្រើប្រាស់ឱ្យបានច្រើន រចនាបថខ្មែរទំនើប “**សហសម័យ**” និងចលនាឱ្យកាន់តែផុសផុលក្នុងការលើកតម្កើងរចនាបថស្ថាបត្យកម្មខ្មែរ ព្រមទាំងពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់។

**អទិភាពទី៩ ÷ ការងារលំនៅឋាន** ដោយរៀបចំលំនៅឋានសមរម្យគួរឱ្យរស់នៅ និងមានបរិស្ថានល្អប្រកបដោយសុខដុមតាមរយៈការរៀបចំគម្រូផ្ទះសម្រាប់យកជាមូលដ្ឋាន ព្រមទាំងរៀបចំគម្រូបុរីជនបទ ការកែលម្អលំនៅឋាន ភូមិចាស់ និងគម្រូលំនៅឋានសម្រាប់ទីតាំងថ្មីៗ។

**អទិភាពទី១០ ÷ ការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុង** ដើម្បីសម្រេចគោលបំណងនៃការកសាងរដ្ឋបាលសាធារណៈទំនើប ការតម្រង់ទិសការងារឱ្យកាន់តែសមស្របតាមមុខងារសាធារណៈ ការបង្កើនប្រសិទ្ធការងារ ពិសេសការពង្រឹងគុណភាពសេវា និងការបង្កើនប្រសិទ្ធភាព ក្នុងការដោះស្រាយវិវាទដីធ្លីឱ្យបានលឿនហើយដាច់ស្រេច ដើម្បីឈានដល់ចុះបញ្ជីបានលឿន។

**អទិភាពទី១១ ÷ ការងារលំនៅឋានសម្បទានដីសង្គមកិច្ច** តាមរយៈការអភិវឌ្ឍលំនៅឋានដីសង្គមកិច្ចប្រកបដោយចីរភាព ពិសេសផលិតកម្មកសិកម្ម ប្រព័ន្ធគាំពារសង្គមកិច្ច សេវាអប់រំនិងសុខាភិបាល ព្រមទាំងសេវាសង្គមកិច្ចនានា ដែលអាចទ្រទ្រង់ការអភិវឌ្ឍសហគមន៍ ពិសេសនិរន្តរភាពជីវភាព និងសេដ្ឋកិច្ចគ្រួសារ។

**អទិភាពទី១២ ÷ ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិ** ក្នុងស្មារតីដើម្បីជាឧត្តមប្រយោជន៍ដល់ប្រជាជន។

**អទិភាពទី១៣ ÷ ការអភិវឌ្ឍធនធានមនុស្ស** តាមរយៈការពង្រឹងសមត្ថភាពបន្ថែមទៀតលើជំនាញបច្ចេកទេស ក៏ដូចជាការងារដឹកនាំគ្រប់គ្រង សម្រាប់ចូលរួមកាន់តែសកម្មលើការងាររដ្ឋបាលទំនើប និងពង្រឹងសមត្ថភាពស្ថាប័ន។

**អទិភាពទី១៤ ÷ ការលើកម្ពស់ការយល់ដឹងក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ដើម្បីលើកកិត្យានុភាពកម្ពុជាបន្ថែមទៀតលើឆាកអន្តរជាតិ ដែលអនុញ្ញាតឱ្យមជ្ឈដ្ឋានជាតិនិងអន្តរជាតិកាន់តែមានជំនឿទុកចិត្តលើកម្ពុជា ព្រមទាំងផ្តល់ព័ត៌មានចំណេះដឹងកាន់តែទូលំទូលាយ បន្ថែមទៀតដល់សាធារណៈជន។

**អទិភាពទី១៥ ÷ កិច្ចការសន្តិសុខនយោបាយនិងកិច្ចការសន្តិសុខសេដ្ឋកិច្ច** តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការគ្រប់ដៃគូអភិវឌ្ឍន៍ និងប្រទេសដៃគូក្នុងអាស៊ាន ដើម្បីរក្សាជំហរពហុភាគីនិយម និងតុល្យភាពនយោបាយផ្ទៃក្នុង និងនយោបាយការបរទេស ព្រមទាំងខិតខំដោះស្រាយបញ្ហានានាដែលអាចជះឥទ្ធិពលដល់ស្ថេរភាពនយោបាយ។